ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន

លេខៈ ..២៧០៤ សលណ.ន..../គ.ជ.អ.ប

ថ្ងៃព្រហស្បតិ៍ ១១រោច ខែពិសាខ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី១០........ ខែឧសភា.. ឆ្នាំ២០១៨

# សេចក្តីណែនាំ

## ស្តីពីការអនុវត្តវិធាន និងនីតិវិធីចំណាយ សម្រាប់ការអនុវត្តសកម្មភាពនានានៃការអភិវឌ្ឍសមត្ថភាព ក្នុងក្របខ័ណ្ឌលេខាធិការដ្ឋាន គ.ជ.អ.ប.

### ១. សេចក្តីផ្តើម

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបានទទួលស្គាល់ និងដាក់ឱ្យអនុវត្តជាអង្គភាពថវិកាចាប់ពីថ្ងៃទី០១ មករា ឆ្នាំ២០១៨ តាមរយៈប្រកាសអន្តរក្រសួងលេខ ៩១៥៣ ប្រ.ក ចុះថ្ងៃទី២៩ ធ្នូ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិការវាងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ។ ក្នុងន័យនេះ ការចំណាយសម្រាប់ការអនុវត្តសកម្មភាពនានានៃផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ (ផ.ស.ថ.) ត្រូវអនុវត្តតាមវិធាន និងនីតិវិធីនានានៃក្រសួង ស្ថាប័នថវិកាកម្មវិធីដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដូចជា ប្រកាសលេខ៨៣៨ សហវ.ប្រក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីវិធាន និងនីតិវិធីចំណាយសម្រាប់វគ្គបណ្តុះបណ្តាល និងសិក្ខាសាលានៃក្រសួង ស្ថាប័នថវិកាកម្មវិធីជាដើម។

### ២. គោលបំណង និងគោលដៅ

សេចក្តីណែនាំនេះមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ តម្លាភាព និងភាពទាន់ពេលវេលានៃការអនុវត្តសកម្មភាពអភិវឌ្ឍសមត្ថភាពនានារបស់លេធិការដ្ឋាន គ.ជ.អ.ប. និងស្ថាប័នអនុវត្តពាក់ព័ន្ធផ្សេងទៀត។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សេចក្តីណែនាំនេះមានគោលដៅកំណត់វិធាន និងនីតិវិធីចំណាយសម្រាប់ការអនុវត្តសកម្មភាពអភិវឌ្ឍសមត្ថភាពនានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប. និងស្ថាប័នអនុវត្តពាក់ព័ន្ធផ្សេងទៀតដែលទទួលបានមូលនិធិគាំទ្រពីលេខាធិការដ្ឋាន គ.ជ.អ.ប.។

### ៣. វិសាលភាពនៃការអនុវត្ត

សេចក្តីណែនាំនេះមានវិសាលភាពអនុវត្តក្នុងក្របខ័ណ្ឌលេខាធិការដ្ឋាន គ.ជ.អ.ប. ដែលជាស្ថាប័នថវិកាកម្មវិធី ដែលផ្តល់ហិរញ្ញប្បទានដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍនានារួមបញ្ចូលទាំងមូលនិធិដែល


មហាវិថីព្រះនរោត្តមៈ លេខាធិការដ្ឋាននៃគ.ជ.អ.ប ក្រសួងមហាផ្ទៃ ។ ទូរស័ព្ទៈ (៨៥៥-២៣) ៧២០ ០៦១ / ៧២០ ០៣៨ E-mail: info@ncdd.gov.kh Website: www.ncdd.gov.kh
Norodom Blvd., National Committee for Sub-National Democratic Development Secretariat (NCDDS). Ministry of Interior. Tel: (855-23) 720 061 / 720 038

គ.ជ.អ.ប. បានវិភាជឱ្យស្ថាប័នអនុវត្តនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ៤. មន្ត្រីបង្គោលក្នុងការរៀបចំ និងការអនុវត្តសកម្មភាពអភិវឌ្ឍសមត្ថភាព

ជាទូទៅ សកម្មភាពសំខាន់ៗនៃការអភិវឌ្ឍសមត្ថភាពមានដូចជា ៖

- **ការបណ្តុះបណ្តាល** សំដៅលើសកម្មភាពទាំងឡាយណាដែលរៀបចំឡើង ដើម្បីផ្តល់ចំណេះដឹង និង/ឬជំនាញជាក់លាក់ណាមួយដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងអ្នកពាក់ព័ន្ធផ្សេងទៀតនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងគោលបំណងសម្រេចបាននូវលទ្ធផល និងសមិទ្ធផលរំពឹងទុកនានានៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
- **សិក្ខាសាលា** សំដៅលើសកម្មភាពនៃការផ្សព្វផ្សាយ ការពិគ្រោះយោបល់ ការណែនាំ ឬការផ្លាស់ប្តូរបទពិសោធន៍ដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីបង្កើនប្រសិទ្ធភាពនៃការរៀបចំ និងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
- សកម្មភាពនៃការអភិវឌ្ឍសមត្ថភាពតាមរយៈវិធីសាស្ត្រផ្សេងទៀតដូចជា ការបណ្តុះបណ្តាលនៅនឹងកន្លែងធ្វើការ ការបង្វឹកនិងការសម្របសម្រួល និងការរៀបចំទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ជាដើម។

ក្នុងការរៀបចំ ការសម្របសម្រួល និងការអនុវត្តសកម្មភាពខាងលើនេះ ទាមទារនូវមន្ត្រីបង្គោលដែលមានសត្ថភាព និងជំនាញសមស្រប ផ្អែកតាមប្រធានបទ គោលបំណង វិសាលភាព និងវិធីសាស្ត្រនៃការអភិវឌ្ឍសមត្ថភាពនីមួយៗ។ ជារួម មន្ត្រីបង្គោលសម្រាប់ការអភិវឌ្ឍសមត្ថភាពរួមមាន ៖

- **គ្រូឧទ្ទេស** ជាអ្នកដើរតួសំខាន់ក្នុងការផ្តល់ចំណេះដឹង និងជំនាញដល់សិក្ខាកាម និងអ្នកចូលរួមនានានៃសកម្មភាពអភិវឌ្ឍសមត្ថភាព តាមរយៈការធ្វើបទធ្វើបទបង្ហាញ ការធ្វើបទឧទ្ទេសនាម ការធ្វើបាឋកថា និងការចែករំលែកបទពិសោធន៍ជាដើម។
- **អ្នកសម្របសម្រួល** សំដៅលើអ្នកទទួលខុសត្រូវក្នុងការរៀបចំ និងការសម្របសម្រួលសកម្មភាពនៃការអភិវឌ្ឍសមត្ថភាពដូចជា ការរៀបចំកម្មវិធីវគ្គបណ្តុះបណ្តាល ការកាន់កម្មវិធី ការបែងចែក និងការសម្របសម្រួលក្រុមពិភាក្សាពិភាក្សា និងការរៀបចំឯកសារវគ្គជាដើម។
- **ជំនួយការ** សំដៅលើអ្នកមានភារកិច្ចគាំទ្រអ្នកសម្របសម្រួលរៀបចំ និងអនុវត្តសកម្មភាពអភិវឌ្ឍសមត្ថភាពមានដូចជា ការរៀបចំរបាយការណ៍វគ្គបណ្តុះបណ្តាល ការកត់ត្រាលទ្ធផលក្រុមពិភាក្សា ការជួយបំភ្លឺនិងឆ្លើយចម្ងល់ផ្សេងៗក្នុងក្រុមពិភាក្សា និងកិច្ចការពាក់ព័ន្ធផ្សេងទៀត។

## ៥. វិធាន និងនីតិវិធីអនុវត្ត

ជាគោលការណ៍ មន្ត្រីបង្គោល និងចំណាយនានាសម្រាប់ការរៀបចំ និងការអនុវត្តសកម្មភាពអភិវឌ្ឍសមត្ថភាព ត្រូវបានកំណត់ដូចខាងក្រោម ៖

១. គ្រូឧទ្ទេស

- ចំនួនគ្រូឧទ្ទេស ប្រែប្រួលស្របតាមប្រធានបទ និងកម្មវិធីអភិវឌ្ឍសមត្ថភាពនីមួយៗ។

- ចំណាយឧបត្ថម្ភគ្រូឧទ្ទេស ផ្តល់ជូនចំនួន៨០.០០០រៀល/១នាក់/១ម៉ោង សម្រាប់រយៈពេលកម្រិតអតិបរមាចំនួន៨ម៉ោងក្នុងមួយថ្ងៃ។

២. អ្នកសម្របសម្រួល និងជំនួយការ

- ផ្តល់ជូនអ្នកសម្របសម្រួលចំនួន១នាក់ និងជំនួយការចំនួន១នាក់ សម្រាប់សកម្មភាពអភិវឌ្ឍសមត្ថភាពដែលមានអ្នកចូលរួមតិចជាង ឬស្មើ៣០នាក់
- ចំនួនអ្នកសម្របសម្រួល និងជំនួយការ អាចកើនទៅតាមសមាមាត្រ ដោយយកចំនួនអ្នកចូលរួមសរុបចែកនឹងចំនួន៣០នាក់។ ក្នុងករណី មានសំណល់លើសពី ១០ ត្រូវផ្តល់ជូនអ្នកសម្របសម្រួលចំនួន១នាក់ និងជំនួយការចំនួន១នាក់ បន្ថែមទៀត។
- ចំណាយឧបត្ថម្ភអ្នកសម្របសម្រួល និងជំនួយការ ត្រូវបានកំណត់ដូចខាងក្រោម ៖
    - អ្នកសម្របសម្រួលផ្តល់ជូនចំនួន៨០.០០០រៀល/១នាក់/១ថ្ងៃ។
    - ជំនួយការផ្តល់ជូនចំនួន៤០.០០០រៀល/១នាក់/១ថ្ងៃ។

ក្នុងករណីខ្លះ គ្រូឧទ្ទេសអាចមានតួនាទី ឬត្រូវបានបែងចែកឱ្យទទួលខុសត្រូវជាអ្នកសម្របសម្រួល ឬជាជំនួយការផងដែរ។ ក្នុងករណីនេះ ប្រាក់ឧបត្ថម្ភសរុបសម្រាប់គ្រូឧទ្ទេស ត្រូវគណនាស្របតាមតួនាទី និងរយៈពេលនៃការបំពេញការងារតាមតួនាទីទាំងនោះ។ ករណីនេះ ត្រូវអនុវត្តដូចគ្នាចំពោះអ្នកសម្របសម្រួល និងជំនួយការផងដែរ។

សេចក្តីណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.**

អនុប្រធានប្រតិបត្តិ

**ខៀវ ប៊ុនឆឿន**